ទីស្តីការក្រសួងយុត្តិធម៌
លេខ ៧២៧.របៈ.៦០៦១-៩៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការគ្រប់ខេត្ត ក្រុង**

**ព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង**

**កម្មវត្ថុ:** អំពីការសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិតក្នុងឱកាសបុណ្យពិសាខបូជា ។

**យោង:** លិខិតលេខ ២៣១ រ.វ ចុះថ្ងៃទី០៥-០៥-៩៤ របស់អគ្គនាយកដ្ឋានព្រះបរមរាជវាំង ។

លិខិតលេខ ៦០៣ ខុ.ទូ-៩៤ របស់ខុទ្ទកាល័យ រាជរដ្ឋាភិបាលកម្ពុជា ។

ខ្ញុំសូមជម្រាបថា តាមព្រះរាជឱង្ការព្រះករុណាជាម្ចាស់ជីវិតលើត្បូង នាអង្គប្រជាសវនាការលើកទី ៤ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ១៩៩៤ នៅប្រាសាទភោជនីយ ព្រះករុណាព្រះអង្គទ្រង់មានព្រះរាជយោបល់យកថ្ងៃបុណ្យពិសាខបូជា ជាថ្ងៃសម្រាប់បន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិតបន្ថែមទៀត ។

ដូច្នេះការស្នើរសុំបន្ធូរបន្ថយទោស និងលើកលែងទោស ត្រូវធ្វើ ៣ ក្នុង ១ ឆ្នាំ គឺ ៖

-នៅពេលព្រះរាជពិធីបុណ្យតាំងតុ

-នៅពេលបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ

-នៅពេលបុណ្យពិសាខបូជា

ឯទម្រង់បែបបទត្រូវធ្វើតាមសេចក្តីណែនាំ នៃទម្រង់បែបបទដែលក្រសួងបានណែនាំពីមុនមកគ្មានការកែប្រែទេ ។

អាស្រ័យហេតុនេះ សូមលោកប្រធានតុលាការ និងព្រះរាជអារាជ្ញាអមតុលាការ ខេត្ត ក្រុង ធ្វើសំណើនេះឡើងដោយយកចិត្តទុកដាក់ពិនិត្យពីឈ្មោះទណ្ឌិត ថ្ងៃ ខែ ឆ្នាំ ចាប់ខ្លួន និងលេខ ថ្ងៃ ខែ ឆ្នាំ សាលក្រម ឱ្យបានត្រឹមត្រូវ ដោយបញ្ជូនភ្ជាប់មក តាមសំណើនូវសាលក្រមទាំងនោះផង ។

<u>-ជនភ្ជាប់មកជាមួយនូវៈ</u>

-សេចក្តីចតចម្លងលិខិតអគ្គនាយកដ្ឋានព្រះបរមរាជវាំង............០១ច្បាប់

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ

-អភិបាលខេត្ត ក្រុង

-ប្រធានតុលាការកំពូល

-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-ប្រធានសាលាឧទ្ធរណ៍

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ប្រធានតុលាការយោធា

-ព្រះរាជអាជ្ញាអមតុលាការយោធា

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**